## បាត់សំឡេង

តំណក់ញើសដណ្ដើមគ្នាហូរមកផ្សើមរាងកាយខ្ញុំជោកជាំកណ្ដាលចំហាយ ម៉ាស៊ីនត្រជាក់ដែលកំពុងតែបញ្ចេញអនុភាពត្រជាក់ស្រេង។ ខ្ញុំសម្លឹងផ្ដោតទៅសាកសពឆវីរីន ពិធីការ នីដ៏មានប្រជាប្រិយភាពបំផុតរបស់ស្ថានីយវិទ្យុ ហើយដែលមុនប្រមាណជា១០នាទី ខ្ញុំទើបតែឮសូរសំឡេងស្រទន់ពីរោះរបស់នាងបង្ហើរតាមរលកធាតុ អាកាសនៅឡើយ។ សាកសពនៅស្រស់ញញឹម ត្រូវបានធ្វើឃាតដោយការរឹតកផ្ដាច់ដង្ហើម ហើយឧបករណ៍ដែលឃាតកប្រើប្រាស់សម្រាប់អំពើឃាតកម្មនេះ គឺជាខ្សែភ្លើងមួយខ្សែដែលវាបន្សល់ទុកក្បែរជើងកៅអី។ ឆវីរីនស្លាប់នៅលើកៅអីក្បែរមីក្រូហ្វូន បានន័យថា នាងត្រូវបានគេសម្លាប់ក្នុងពេលដែលនាងកំពុងបំពេញការងារ...។

ខ្ញុំឈរផ្អែកជញ្ជាំងដោយហេងហាងក្នុងចិត្ត... ខ្ញុំគិតហើយគិតទៀត គិតរហូតស្ទើរតែងងឹតមុខដួលដោយគិតមិនយល់ថា ហេតុអ្វីរឿងនេះកើតឡើងនៅកន្លែងខ្ញុំ?ហេតុអ្វីបានជាគេសម្លាប់ នាង? ហើយគេនោះជាអ្នកណា?

លោកនាយក!

សំឡេងហៅមួយឃ្លានេះ ថ្វីត្បិតតែលាន់ឮតិចៗមែន តែវាមានឥទ្ធិពលអាចធ្វើឲ្យខ្ញុំភ្ញាក់ដូចគេកន្ត្រាក់ ព្រោះស្មារតីរបស់ខ្ញុំ កំពុងត្រូវបានរវើរវាយទៅតាមការស្លាប់យ៉ាងទាន់ហន់របស់ឆវីរីន ស្ទើរតែអស់រលីងពីរាងកាយទៅហើយ...។

ខ្ញុំងាកមករកម្ចាស់សំឡេងដែលនៅឈរកៀកនឹងខ្ញុំ ពីពេលណាមកក៏មិនដឹង ។ក្រសែភ្នែកភ្លឺមុតដែលជះសម្លឹងមកខ្ញុំ ខ្ញុំរឹតតែបង្កើតអោយខ្ញុំនូវអារម្មណ៍មិនស្រួលទ្វេឡើង ។

ខ្ញុំតាំងស្មារតីតបទៅវិញ៖

បាទ?

នាយប៉ូលិសវ័យក្មេង តបមកកាន់ខ្ញុំដោយទឹកមុខស្មើធេង៖

ដោយសារតែជនរងគ្រោះត្រូវធ្វើឃាតក្នុងបន្ទប់ផ្សាយ ហើយនៅស្ថានីយវិទ្យុដែលលោកគ្រប់គ្រងដោយផ្ទាល់ ដូច្នេះសូមលោកជួយសម្រួលដល់ប៉ូលិសក្នុងការអង្កេតផង...!

ខ្ញុំពោលសួរបន្ថែមទាំងគ្មានអារម្មណ៍នឹងនបន្តិចសោះ ៖

ថាមកចុះ!ខ្ញុំត្រូវធ្វើអ្វីខ្លះ?

នាយប៉ូលិសរូបនេះតបមកវិញដោយអាការៈមាំទាំ ៖

ប៉ូលិសសូមឃាត់ខ្លួនមនុស្សទាំងអស់ដែលមានវត្តមាននៅទីនេះដើម្បី សួរចម្លើយ រួមទាំងលោកផង !មុនពេលមានការអនុញ្ញាត អត់មានអ្នកណាអាចចេញបានទេ !

ក្រោមពន្លឺម៉ាស៊ីនថតដែលក្រុមអ្នកសារព័ត៌មានកំពុងប្រជ្រៀតចុច ពីមាត់ទ្វារបន្ទប់ទោះបីប៉ូលិសព្យាយាមរារាំងយ៉ាងណាក្តីនោះ ខ្ញុំក៏ដឹងដែរថា ខ្ញុំគ្មានលទ្ធភាពអ្វីដើម្បីរាំងកិច្ចការរបស់ប៉ូលិសបានឡើយ បានត្រឹមតែឈរទ្រឹងសម្លឹងសពឆវីវីន សហ ការិនីដ៏ល្អដែលកំពុងត្រូវបានក្រុមជំនាញលើកបញ្ជូនចាកចេញ ពីស្ទូឌីយោលេខ៧ ទីដែលនាងនឹងមិនត្រឡប់មកវិញជារៀងរហូត។

ខ្ញុំងាកទៅរកសហាការីក្រោមបង្គាប់ផ្សេងទៀត ដែលកំពុងមានវត្តមាននៅទីនេះទាំងអស់គ្នា ខ្ញុំឃើញនាងម៉ាណាកំពុងឈ្ងោកមុខយំសស្រាក់ ក្បែរនោះម៉ានិតដេត ភ្នែកក្រហមស្ទើរស្រក់ឈាម ហើយនាយថូនីវិស្វករ ដែលទើបនឹងអញ្ជើញមកពីអាមេរិកបានប្រមាណមិនដល់៣ខែផងនោះ ក៏កំពុងមុខខ្មៅប៉ែឈរស្ងៀមលែងនិយាយស្តីដែរ។ ងាកទៅម្ខាងទៀត នាងទុំក្មេងស្រីជំទង់កូនអ្នកជនបទម្នាក់ ដែលខ្ញុំជួលឲ្យមកធ្វើ ការជាអ្នកលើកទឹក និងបោសសម្អាតនៅស្ថានីយវិទ្យុនេះ កំពុងសសៀរខ្លួនរកចាកចេញពីបន្ទប់ផ្សាយដោយដើរតិចៗសំដៅទៅរកមាត់ ទ្វារទាំងមុខស្លាំង ប៉ុន្តែអធិការប៉ូលិសវ័យក្មេង ដែលអម្បាញ់មិញ នៅឈរក្បែរខ្ញុំនៅឡើយ ស្ទុះទៅរាំងពីមុខជាប់ ដោយពោលម៉ាត់ៗទៅកាន់នាង ៖

ប៉ូលិសមិនទាន់អនុញ្ញាតឲ្យអ្នកណាម្នាក់ចេញពីទីនេះទេនាង !

ក្មេងស្រីលើកទឹក មុខស្លាំងលើសដើម នាងងាកមកសម្លឹងមុខខ្ញុំ របៀបសុំជំនួយ ខ្ញុំក៏ពោលទៅកាន់ប៉ូលិសនោះ ៖

លោកប៉ូលិស ! ក្មេងស្រីនេះឆាប់ស្លុតណាស់ សូមអនុញ្ញាតឲ្យនាងទៅផ្ទះវិញសិនបានទេលោក ?

ប៉ូលិសរូបនេះ ងាកមកសម្លឹងខ្ញុំថ្មៃ គេពោលមួយៗ តែវាចាមួយម៉ាត់ៗមុតដូចកាំបិត ៖

លោកនាយក អ្នករងគ្រោះត្រូវគេសម្លាប់នៅទីនេះ ឥលូវអ្នកណាជាឃាតក ក៏មិនទាន់រកឃើញ ហេតុនេះអ្នកដែលមានវត្តមាននៅទីនេះទាំងប៉ុន្មាន គឺសុទ្ធសឹងតែត្រូវជាប់សង្ស័យទាំងអស់ បើមិនទាន់ឆ្លងកាត់ការសួរចម្លើយទេ អ្នកណាក៏ចេញមិនបានដែរ។

ខ្ញុំធ្លាក់ថ្លើមក្តុកដូចកំពុងដឹងថា ខ្លួនជិតត្រូវគេចាប់បោះទម្លាក់ក្នុងសមុទ្រដូច្នេះដែរ បានន័យថា ខ្ញុំនិងសហការីទាំងអស់ដែលមានវត្តមាននៅទីនេះ កំពុងជាប់សង្ស័យពីបទសម្លាប់មនុស្សហើយ? ដែល

ប្រការនេះ ខ្ញុំមិនធ្លាប់គិតដល់សោះថា ក្នុងចំណោមពួកយើងទាំង៥នាក់ មាននរណាម្នាក់ជាឃាតក សម្លាប់ឆវីរីនោះ?

ខ្ញុំសម្លឹងទៅនាងទុំ ក្មេងអ្នកលើកទឹកឃើញនាងបើកភ្នែកគ្រលួងសម្លឹងទៅមានិតដេតភ្លៀកៗ រួចយំង៉ោង... ប្រហែលជាសភាពការណ៍ដ៏គួរឲ្យតក់ស្លុតបែបនេះ នាងមិនធ្លាប់ជួបប្រទះពីមុនមកទេ ដូច្នេះហើយបានជាមិនអាចទប់ស្មារតីបាន ទ្រហោយំឥតអៀនខ្មាសដូច្នេះ។

សំឡេងមួយផ្សេងទៀតលាន់មកលាន់ក្រអៅ ៖

បំបែកមនុស្សសួរចម្លើយ !

ខ្ញុំងាកភ្លែតទៅរកមាត់ទ្វារទាំងអរភើតក្នុងចិត្តព្រោះស្គាល់ថា ជាសំឡេងរបស់វិចិត្រប្អូនប្រុសជីដូនមួយខ្ញុំ។

ពិតណាស់ស្ថានីយវិទ្យុនេះស្ថិតនៅក្នុងមូលដ្ឋានដែលប្អូនប្រុស ខ្ញុំគ្រប់គ្រង ... ដូច្នេះតាមមើល ការអង្កេតករណីឃាតកម្មនេះ គឺក្រុមវិចិត្រប្អូនប្រុសខ្ញុំមកធ្វើ ឃើញថាខ្ញុំរាងធូរចិត្តជាងមុនបន្តិច។ វិចិត្រជាប៉ូលិសយូរឆ្នាំមកហើយ... ក៏អាស្រ័យដោយបញ្ញាវាងវៃ និងបទពិសោធន៍គ្រប់គ្រាន់ ក្នុងការងារនេះដែរ ដែលគេអាចទទួលឋានៈជានាយប៉ុស្តិ៍វ័យក្មេងជាមួយនឹងស្នាដៃក្រាស់ ក្រែលរួចមកហើយ ។លើករណីឃាតកម្មនៅស្ទូឌីយោលេខ៧លើកនេះ បើប្អូនខ្ញុំគេចុះធ្វើផ្ទាល់ហើយ ខ្ញុំមានសង្ឃឹមច្រើនក្នុងការរកមុខឃាតក។

ពួកយើងត្រូវប៉ូលិសបំបែកនាំទៅសួរចម្លើយនៅបន្ទប់ផ្សេងៗពីគ្នា សំណាងល្អដោយវិចិត្រប្អូនប្រុសខ្ញុំគឺជាអ្នកសួរចម្លើយខ្ញុំដោយផ្ទាល់ ដូច្នេះអារម្មណ៍ខ្ញុំមិនអាក្រក់ដូចពេលមុននេះប៉ុន្មានទេ។

៥នាទីកន្លងដែលខ្ញុំលង់ក្នុងភាពខ្វល់ខ្វាយ សំឡេងគ្រហែមរបស់គេធ្វើអោយខ្ញុំងើបមុខឡើងវិញប្រឈមទៅនឹងការពិត ដែលទាមទារអោយ ខ្ញុំត្រូវតែរួមចំណែកដោះស្រាយ។ខ្ញុំក្រឡេកទៅរកទឹកមុខស្មើធេងដែល វិចិត្រកំពុងឈ្ងោកសម្លឹងឯកសារមួយសំណុំក្នុងដៃ... ខ្ញុំមិនអាចទប់ចិត្តទ្រាំរក្សាការស្ងៀមស្ងាត់តទៅទៀតបានឡើយ... ខ្ញុំពោលសួរគេទាំងច្របូកច្របល់ចិត្ត ៖

រកឃើញដានអីខ្លះទេ?

ប្អូនប្រុសជីដូនមួយខ្ញុំជ្រួញចិញ្ចើមទាំងគូចូលគ្នា បង្ហាញភាពស្មុគស្មាញ ខ្ញុំឃើញគេបន្តពិនិត្យឯកសារដោយយកចិត្តទុកដាក់ និងស្ងៀមស្ងាត់ ... ខុសប្លែកពីចិត្តខ្ញុំ ដែលកំពុងពុះកញ្ជ្រោលចង់ដឹងការពិតក្នុងរឿងនេះ...។

ទ្រនិចនាឡិកាចង្អុលម៉ោង១០និងង១៦នាទី ខ្ញុំផ្អែកខ្នងលើបង្អែកកៅអីទាំងធូន់ពាប់ក្នុងអារម្មណ៍ ។ផ្លាកស្វូឌីយោលេខ៧ដែលនៅឆ្ងាយពីនេះមិនដល់៣ជំហ៊ាន លេចឡើងក្នុងចិត្តខ្ញុំ ។ហេតុអ្វី?ហេតុអីគេរើសយកទីនេះសម្រាប់សម្លាប់នាង ហេតុ អីហេតុការណ៍ដ៏អាក្រក់នេះកើតឡើងចំពោះទីតាំងអាជីវកម្មរបស់ខ្ញុំ ?

សំឡេងវិចិត្របន្លឺមកកាន់ខ្ញុំនូវឃ្លាដំបូងបង្អស់៖

បងវិសុទ្ធ ! កន្លងមកបងធ្លាប់ដឹងទេថា ឆវីរីនធ្លាប់មានទំនាក់ទំនងជាមួយនរណាខ្លះ?

ខ្ញុំលើកដៃច្បូតមុខទាំងតប់ប្រមល់ ខ្ញុំពិតជារកនឹកមិនឃើញនូវតម្រុយណាមួយ ដើម្បីឆ្លើយតបទៅប្អូនជីដូនមួយខ្ញុំសោះ ខ្ញុំពោលប្រាប់គេវិញត្រង់ៗតែម្តង ៖

វិចិត្រ ! មិនមែនបងចង់កាន់ជើងបុគ្គលិកទេ តែពីមុនមក អារីនក្រៅពីមានសមត្ថភាពស័ក្តិសមជាបុគ្គលិកគំរូ ឯងឃើញហើយ នាងស្អាត សំឡេងពីរោះគេចូលចិត្តទៀត បើនិយាយតាមពិតទៅ មានតែមនុស្សស្រលាញ់ប៉ុណ្ណោះ មិនដែលឃើញមានទំនាស់ជាមួយអ្នកណាទេ !

វិចិត្រញាក់ស្មាតបមកវិញភ្លាមដោយទឹកមុខស្មើ ៖

ឬមួយគុណសម្បត្តិទាំងអស់នេះទេដឹង ដែលធ្វើឲ្យនាងមានគ្រោះថ្នាក់?

អធិការវ័យក្មេងប្អូនប្រុសខ្ញុំតបវិញដោយលើកសំណុំឯកសារក្នុងដៃបង្ហាញខ្ញុំផង ៖

ប៉ូលិសគេបានកត់ត្រាមកថា ... ស្ថានភាពឆវីរីនគឺត្រូវឃាតករឹតកសម្លាប់លើកៅអីអង្គុយទល់មុខម៉ាស៊ីនចាក់ផ្សាយ។ បានន័យថា ពេលនោះនាងកំពុងត្រៀមលក្ខណៈ ឬស្ថិតក្នុងពេលបំពេញការងារ...

ខ្ញុំពោលកាត់ ៖

ត្រូវហើយ តាមធម្មតានៅម៉ោង៨ រហូតដល់ម៉ោង១០ព្រឹក គឺជាកម្មវិធីរបស់នាង ..

វិចិត្របន្លឺបន្តដោយសម្លឹងមុខខ្ញុំជាប់ ៖

ហេតុ អីនៅ លើទ្វារបន្ទប់ ផ្សាយនោះមានដាក់ស្លាកថា ស្ទូឌីយោលេខ៧? បងមានបន្ទប់ចំនួនប៉ុន្មានទៅ?

ខ្ញុំដកដង្ហើមយូរមុនតបនឹងសំនួរគេបន្ត ៖

ស្ទូឌីយោមានតែពីរទេ មួយទុកថតនិងមួយទៀតផ្សាយផ្ទាល់ចេញ?

នៅពេលចិញ្ចើមនាយប៉ូលិសមិនទាន់រសាយចេញពីចម្ងល់ ខ្ញុំចាំបាច់ត្រូវអធិប្បាយបញ្ជប់ចម្ងល់របស់គេ៖

បង រើសយកលេខ៧មក ដាក់លើបន្ទប់ ផ្សាយដោយសារគ្រូ ខាងហុងស៊ុយប្រាប់ ថាលេខនេះតំណាងអោយភាពត្រជាក់ ភោគទ្រព្យនិងជោគជ័យ។

ហាក់បីដូចជាអៀនប្រៀនបន្តិច ដែរនៅពេលដែលលើកយកជំនឿរបៀបនេះមកបរិយាយប្រាប់ប៉ូលិសតែសំណាងល្អ វិចិត្រជាប្អូនខ្ញុំស្រាប់ ណាមួយមិន ឃើញគេមានប្រតិកម្មអីដែរ។ផ្ទុយទៅវិញគេនៅតែបន្តចូលសំនួរបន្ទាប់ ដោយនឹងនះ

ហើយនៅលើទ្វារបន្ទប់ផ្សាយ យើងបានឃើញប្រអប់សោកូដម្យ៉ាងដែលបើក ឬបិទទ្វារដោយលេខសម្ងាត់ អញ្ចឹងប៉ូលិសសង្ស័យជាជំហានដំបូងថា ឃាតកគឺជាមនុស្សស្ថិតនៅក្នុងចំណោមបុគ្គលិកទាំងអស់របស់បងដែល ធ្វើការក្នុងស្ថានីយវិទ្យុនេះខ្ញុំ សំដៅអ្នកដែលមានលេខសំងាត់សម្រាប់ចូលស្ទូឌីយោលេខ៧។

ខ្ញុំធ្លាក់ថ្លើមក្តុក... ម៉េចក៏ខ្ញុំភ្លេចគិតដល់ចំណុចនេះ?ពិតមែនហើយ សោពិសេសប្រើលេខសម្ងាត់សម្រាប់ការពារបន្ទប់ផ្សាយនេះគឺវិស្វករ ថូនី នាំយកមកពីសហរដ្ឋអាមេរិក ជាអំណោយថ្ងៃសម្ពោធស្ថានីយដំបូង។ បន្ទាប់មកគេបានបង្រៀននូវរបៀបបើក និងបិទទ្វារដែលក្រៅពីបុគ្គលិកវិទ្យុ គ្មាននរណាអាចមានលទ្ធភាពបើកទ្វារបន្ទប់ផ្សាយចូល ឬចេញនោះឡើយ។ ឯឆវីវីនក៏មិនខុសពីបុគ្គលិកផ្សេងទៀតដែរ ពួកគេតែងតែបិទទ្វារបន្ទប់ផ្សាយដើម្បីការពារកុំឲ្យមានការរំខាន ណាមួយនៅរាល់ពេលពួកគេកំពុងផ្សាយផ្ទាល់លើរលកអាកាស។ ឬមួយឃ្លាថា ឃាតកដែលអាចបើកទ្វារចូលទៅសម្លាប់ឆវីវីន គឺជាមនុស្សក្នុងចំណោមបុគ្គលិករបស់ខ្ញុំដែលកំពុងមានវត្តមាននៅ ទីនោះមែន?

សំឡេងវិចិត្របន្លឺមកកាន់ខ្ញុំសាជាថ្មី ៖

នៅមានចំណុចមួយទៀត ដែលយើងត្រូវពិចារណា!បងសាកល្បងវិភាគទៅមើល ... ស្ថានភាពបន្ទប់ផ្សាយរបស់វិទ្យុបងមានលក្ខណៈបិទជិតឈឹងសូម្បីបង្អួចមួយក៏ គ្មាន ដូច្នេះចង់ចូលមកខាងក្នុង គឺត្រូវឆ្លងកាត់ទ្វារជាចាំបាច់... ឯទីតាំងរបស់ម៉ាស៊ីនចាកផ្សាយ គឺបែរមុខមកចំទ្វារ... ដូច្នេះពេលដែលឃាតក បើកសោចូលទៅ... ចង់មិនចង់ឆវីវីន ត្រូវតែមើលឃើញឃាតក ចុះហេតុអ្វីនាងមិនរត់គេច? ម៉េចក៏នាងនៅអង្គុយស្ងៀមលើកៅអីបណ្តោយឲ្យឃាតកចូលមកក្នុងបន្ទប់ ផ្សាយ ហើយដើរមករឹតកពីក្រោយបាន?

ភាពសង្ស័យលេចធ្លោព្រម ៗគ្នាក្នុងអារម្មណ៍ខ្ញុំ... ខ្ញុំភ្លាត់មាត់កាត់សម្តីវិចិត្តៈ

បានន័យថា ?

វិចិត្រងក់ក្បាលផ្ងក់ៗ គេពោលបន្តៈ

ឃាតក និងជនរងគ្រោះគឺជាមនុស្សដែលស្គាល់គ្នា អាចថាជិតស្និទ្ធ រឺឃើញគ្នារាល់ថ្ងៃចេញចូលស្ទូឌីយោនេះរឿយៗ ជាហេតុអោយឆវីរីនមិនចាប់អារម្មណ៍ថា... ឃាតកចូលមកលើកនេះ... គឺមកធ្វើឃាតនាង!

កាន់តែស្តាប់ កាន់តែវិលវល់ក្នុងចិត្ត ខ្ញុំទទួលស្គាល់ថា ការសន្និដ្ឋានរបស់វិចិត្រសមហេតុផលល្មមអាចទទួលយកបាន... តែខ្ញុំនៅតែរកនឹកមិនឃើញសោះថា អ្នកណាម្នាក់ក្នុងចំណោមបុគ្គលិកក្រោមបង្គាប់ខ្ញុំទាំងអស់ដែលជា ឃាតកសម្លាប់ឆវីរីន ។

ពួកយើងទាំង៥មកកាន់ក្រុងព្រះសីហនុទើបតែប្រមាណពីរខែមែន តែយើងមិនទើបតែស្គាល់គ្នាទេ។ មុនពេលដែលខ្ញុំមានប្រាក់វិនិយោគលើ ស្ថានីយមួយនេះ ពួក ខ្ញុំបានស្គាល់គ្នា ជាមុនតាំងពីនៅភ្នំពេញម្ល៉េះ ហើយម៉ាណា ម៉ានិតដេត និងឆវីរីនបានរួមការងារជាមួយគ្នាមិនតិចជាង៥ឆ្នាំហើយដែលកាលពីនៅ ភ្នំពេញ។

ខ្ញុំពោលបន្តទៅកាន់វិចិត្រដូចគ្មានអារម្មណ៍គ្រប់គ្រាន់ក្នុងខ្លួន ៖

បើឃាតកស្ថិតក្នុងចំណោមអ្នកធ្វើការនៅទីនេះមែន...ហេតុអ្វីបានជា គេសម្លាប់នាង? នាងជាមនុស្សចិត្តល្អហ្មត់ចត់ និងការងារផង ហើយជួយយកអាសាអ្នកដទៃណាស់ ម៉េចក៏គេសម្លាប់នាង? យើងជាស្ថានីយ ថ្មី តែនាងមានប្រជាប្រិយភាពតាំងពីនៅភ្នំពេញមក គេមិនមែនទើបតែដឹងហើយមកច្រណែននាងទេ! អ្នកណាក៏ចូលចិត្តស្តាប់នាងដែរ ហេតុអ្វីនាងត្រូវស្លាប់ដូច្នេះ?

វិចិត្រប្រហែលជាទើសចិត្តចំពោះភាពរវើរវាយរបស់ខ្ញុំនេះហើយបានជាខ្ញុំឮគេបន្លឺតប ៖

ក្រែងបងថានាងជាស្រីស្អាត មានប្រជាប្រិយភាព មានសមត្ថភាព មានគេចូលចិត្តច្រើនអ្ហែស? មនុស្សមានគុណសម្បត្តិច្រើនយ៉ាងពេកមិន ប្រាកដថា...អ្នកដទៃទៀតសុទ្ធតែគេពេញចិត្តនោះទេណ៎ាបង !

ខ្ញុំងាកភ្លែតទៅរកវិចិត្រ បន្ទាប់ពីបានឮប្រយោគស្ទើរលេង ស្ទើរមែនរបស់គេ ខ្ញុំសួរជាបន្ទាន់ ៖

ឯងគិតថា មានគេច្រណែននាង... ទើប...?

បើឃាតកជាមនុស្សស្រី... គេសម្លាប់នាងព្រោះច្រណែន... តែបើឃាតកជាប្រុស គេសម្លាប់ព្រោះប្រច័ណ្ឌ ហើយតាមសុំស្នេហ៍មិនសម្រេចក៏ថាបាន តែអ្វីៗទាំងនេះ គ្រាន់តែជាការសន្និដ្ឋានទុកតែប៉ុណ្ណោះ រឿងពិតរវាងអ្នករងគ្រោះ និងឃាតកយ៉ាងណាទេ តាមមើលមានតែអ្នកទាំងពីរនោះទេដែលអាចដឹងបាន ! ...ឥលូវនេះ ... សូមបងជួយពួកខ្ញុំ ក្នុងការអង្កេតនេះផង តាមគំនិតបងដែលបងជាអ្នកគ្រប់គ្រងបុគ្គលិកទាំងអស់នៅទីនេះ... បងមានសង្ស័យចំពោះអ្នកណាម្នាក់ទេ?

ខ្ញុំផ្ទេចភ្នែកសញ្ជឹងគិតទាំងក្បាលណែនធូន់ដោយការស្មុគស្មាញ ...។ខ្ញុំចង់ឆ្លើយណាស់ តែការពិតនៅតែជាការពិត ខ្ញុំគិតមិនឃើញមែន។ ខ្ញុំតបទៅកាន់វិចិត្រមួយៗ ៖

ឯងដឹងស្រាប់ហើយ បុគ្គលិកបងគ្នាមិនច្រើនទេ យើងទើបតែមកដល់ សម្ពោធបានមិនដល់២ខែស្រួលបួល។កាលពីមុន នៅភ្នំពេញ យើងមានគ្នា៥នាក់ជាពិធីករ៥នាក់ ឆវីរីន ម៉ាណា ផានី ម៉ានិតដេត និងឧត្តម... តែផានី និងឧត្តមកាលណោះយើងជួលស្ថានីយគេធ្វើការ។ពេលបងមានស្ថានីយខ្លួនឯង នៅទីនេះ ផានីនិងឧត្តមបដិសេធមិនមកកំពង់សោមទេ អញ្ចឹងយើងមានតែបួននាក់ទេចេញពី ភ្នំពេញមក។ធ្វើការអត់មានចាត់ទុកគ្នាជាមេជាចៅកែអីទេ រាប់អានស្និទ្ធស្នាលគ្នាដូចបងប្អូនធម្មតាបើចង់ឲ្យបងសង្ស័យថានាងម៉ាណា ឬម៉ានិតដេត ជាឃាតកនោះ បងគ្មានយោបល់ទេ ព្រោះវាមិនទំនងសោះមនុស្សហូបបាយជុំគ្នារាល់ថ្ងៃ!បើ ពួកគេមានរឿងអីហ្នឹងគ្នាគួរតែមានយូរណាស់ហើយមិនចាំបាច់ចាំមកដល់វិទ្យុ ថ្មីទេ។

វិចិត្រ សម្លឹងមកខ្ញុំយ៉ាងយកចិត្តទុកដាក់ ហាក់បីដូចកំពុងប្រឹងផ្ទៀងស្តាប់មិនឲ្យបាត់ពាក្យខ្ញុំមួយម៉ាត់ណាអីចឹង។ ភ្លាមនោះគេចាក់សំណួរមកវិញ៖

ចុះក្រៅពីម៉ាណា និងម៉ានិតដេត...មានអ្នកណាមានលេខសម្ងាត់បើកទ្វារបន្ទប់ផ្សាយទៀតដែរទេ?

ខ្ញុំឆ្លើយតបភ្លាម ៖

គឺបងខ្លួនឯងនិងចុងក្រោយគឺវិស្វករ ថូនី ម្ចាស់សោតែម្តង! សោនោះគឺគេយកពីអាមេរិកមកជាអំណោយដល់វិទ្យុយើងក្នុងថ្ងៃ សម្ពោធ !

ថូនី ជាអ្នកណា?(គេសួរវិញភ្លាម)

ខ្ញុំតបពន្យល់តាមការចោទសួររបស់គេ ៖

វិស្វករថូនី គឺជាមិត្តល្អរបស់ម៉ានិតដេត។ គេរស់នៅអាមេរិក ជាកូនខ្មែរយើង តែដឹងក្តីនៅទីនោះ ថូនីគេមកទីនេះគឺជួយបង្រៀនបច្ចេកវិជ្ជាថ្មីៗ ក្នុងការប្រើប្រាស់ម៉ាស៊ីនផ្សាយ និងបច្ចេកទេសកាត់តផ្សេងៗដល់បុគ្គលិកវិទ្យុ...គេជាអ្នកបច្ចេកទេសជើង ខ្លាំងម្នាក់ ! ...

គេមកដល់កម្ពុជាតាំងពីពេលណា?

តាំងពីយើងចាប់ ដំណើរការសង់អង់តែនដំបូង!គេជួយយើងមួយចប់។(ខ្ញុំឆ្លើយដោយគ្មានសង្ស័យ)

អីចឹង តាំងពីព្រឹកព្រលឹមរហូតដល់ពេលឃើញសាកសពឆវីវីននៅទីនេះមានវត្តមានបុគ្គលិកទាំង៤នាក់នោះទេ?

មាន! (ខ្ញុំតបវិញ) ព្រោះបងត្រូវធ្វើការប្រជុំសរុបការងារប្រចាំខែ មិនតែប៉ុណ្ណោះ នាងទុំក្មេងលើកទឹកក៏មកធ្វើការដែរ... បានន័យថា គ្នាយើងទាំង៦នាក់ មកជួបជុំគ្នាទាំងអស់... តែនាងទុំនៅរវល់ការងាររបស់នាងនៅខាងក្រោម ឯឆវីវីនក៏ចូលបន្ទប់ផ្សាយធ្វើកម្មវិធីស្នើសុំបទចម្រៀងតាម ទូរស័ព្ទ ... អីចឹងហើយអ្នកដែលចូលប្រជុំមានតែមានិត ម៉ាណា ថូនី និងបង... ។នាងទុំក្មេងលើកទឹកនោះ វាស្លូតណាស់ ហើយក៏មិនចេះបើកទ្វារបន្ទប់ផ្សាយដែរ ព្រោះមិនស្គាល់លេខសម្ងាត់ ឯម៉ាណា នាងជាមនុស្សស្រី នៅទីនេះមានតែនាង និងឆវីវីន ទេដែលធ្វើការវិទ្យុផង និងចាត់ចែងកិច្ចការរដ្ឋបាលជាមួយគ្នាផង ពួកគេរួមការងារជាមួយគ្នាយូរមកហើយ ហើយក៏ស្និទ្ធស្នាលគ្នាដែរ មិនដែលឃើញទាស់ពាក្យសម្តីគ្នា ឬអាប់អន់ស្រពន់ចិត្តគ្នាអ្វីគួរឲ្យសង្ស័យទេ ... ចំណែកម៉ានិតដេត ជាមនុស្សម៉ត់ចត់ យកចិត្តទុកដាក់នឹងការងារ... ថូនីនោះទៀតជាកូនខ្មែរមែន តែរស់នៅបរទេសតាំងពីតូចចរិតរបស់គេទូលាយរបៀបអឺរ៉ុប គ្មានក្នុងក្រៅអីទេ... ពួកគេទាំង៤ ស្រលាញ់រាប់អានគ្នា ធ្វើការរួមគ្នា ពេលខ្លះប្រឹងប្រែងហួសយប់ព្រលប់ កម្សត់កម្រនឹងគ្នា ព្រោះការងារច្រើន ហើយបុគ្គលិកតិច ... មិនឃើញថា មានចន្លោះណាគួរឲ្យយកមកគិតឃើញថា ពួកគេត្រូវសម្លាប់គ្នាសោះ... បងពិតជាទាល់តម្រិះមែន!

វិចិត្រញាក់ស្មានិយាយទាំងសើចស្រស់ស្រាយ ៖

បើមិនមែនពួកគេ អីចឹងមានតែបងនេះហើយដែលសម្លាប់នាង!

ខ្ញុំដឹងថាប្អូនខ្ញុំកំពុងកំប្លែងលេង ប៉ុន្តែខ្ញុំគ្មានចិត្តណានឹងសើចសប្បាយជាមួយគេទៀតនោះទេ ខ្ញុំផ្អែកខ្នងសាជាថ្មីទៅលើបង្អែកកៅអី ពោលទៅកាន់គេបន្ត ៖

ចាប់តាំងពីម៉ោង៨កន្លះម្ល៉េះ បងនិងបុគ្គលិកទាំង៣នាក់នោះ ចូលប្រជុំក្នុងបន្ទប់នេះ ឯកសារនៅរាត់រាយនៅឡើយ ឯងមើលចុះ... (ខ្ញុំចង្អុលទៅឯកសារទាំងប៉ុន្មានដែលបន្សល់ទុកលើតុប្រជុំពីមុននេះនៅឡើយ...) ខ្ញុំពោលបន្ត៖

រហូតដល់ម៉ោង៩កន្លះ បងនៅឮសំឡេងឆវីវីនតាមវិទ្យុនៅឡើយ... ព្រោះរហូតមក បងបើកវិទ្យុចោលរហូត...

ខ្ញុំឃើញប្អូនប្រុសខ្ញុំគេងាកសម្លឹងទៅវិទ្យុដែលបញ្ឈរចោលលើតុសាឡុងឯជ្រុងម្ខាង... គេពោលសួរមកខ្ញុំវិញភ្លាម៖

អីចឹងនៅពេលណាទើបលែងឮសំឡេងនាង? ...

គឺនៅពេលភ្លើងដាច់នោះហើយ!

យ៉ាងរហ័សដូចផ្លេកបន្ទោរ ខ្ញុំឃើញវិចិត្របើកភ្នែកសម្លឹងមកខ្ញុំយ៉ាងមុត ហាក់បីដូចជាកំពុងសម្លឹងទៅរកហេតុការណ៍ក្នុងពេលនោះអីចឹង ៖

ភ្លើង ដាច់?

ខ្ញុំងក់ក្បាលផ្ងក់ៗ ហើយបន្តបញ្ជាប់ការសង្ស័យរបស់គេ ៖

យើងប្រជុំដល់ម៉ោង ៩កន្លះ ស្រាប់តែដាច់ភ្លើង... យើងលែងបានឮសំឡេងឆវីវីនពីពេលនោះមក ... រយៈពេលប្រហែលមួយនាទីប៉ុណ្ណោះ... ក្រោយពេលបញ្ឆេះម៉ាស៊ីនភ្លើង... យើងនៅតែមិនឮឆវីវីនផ្សាយកម្មវិធីទៀតសោះ ពេលនោះហើយដែលយើងរត់ទៅរកបន្ទប់ផ្សាយហើយដឹងថា នាងត្រូវគេសម្លាប់។

អ្នកណាឃើញសាកសពមុនគេ?(វិចិត្រសួរដោយបើកភ្នែកមូលក្លំ)

គឺបង និងថូនី... នៅពេលដែលវិទ្យុយើងស្ងាត់មិនឮសំឡេងនោះឯងដែលយើងទាំងពីរក្រោក ទៅកាន់បន្ទប់ផ្សាយព្រមៗគ្នា ឯងឃើញហើយ បន្ទប់ផ្សាយ និងOfficeបងនេះ នៅឆ្ងាយពីគ្នាមិនបាន៣ម៉ែត្រផង... ។

បងឃើញអីមុនគេ?ទ្វារស្ទូឌីយោលេខ៧បិទរឺបើក?

អារម្មណ៍ខ្ញុំ វិលខ្វាល់ទៅ រកព្រឹត្តិការណ៍ជាងមួយម៉ោងមុននេះ។ខ្ញុំ ឆ្លើយដោយមិនបាច់គិត៖

គ្រប់យ៉ាងធម្មតា!បងទៅដល់ភ្លាម ឆវីរីន ក្លាយជាសាកសពលែងកម្រើកទៅហើយ... ហុឺ នេះជាហេតុការណ៍អកុសលដែលបងទើបតែប្រទះឃើញជាលើកដំបូងបង្អស់ក្នុង ជីវិតរបស់បង! ..

តែវិចិត្រនៅតែសង្ស័យ៖

ខ្ញុំចង់ដឹងថាទ្វារបិទរឺបើក?

គឺបិទធម្មតា យើងគិតថានាងប្រហែលបើកម៉ាស៊ីនមិន ចេញ រឺមួយErrorអ្វីមួយ បានជាបងនឹងចូ នីស្ទុះចូលទៅ!

នាយប៉ូលិសជីដូនមួយខ្ញុំសើចស្ងួត៖

គឺអ្នកទាំងពីរបានជួយសំអាតក្រយៅដៃឃាតកផងដែរ!

ខ្ញុំ គ្រវីក្បាលតិចៗជាសញ្ញាថាអត់តម្រិះគិតដល់រឿងហ្នឹងទេ។

ក្នុងពេលជាមួយគ្នានោះ វិចិត្រជ្រួញចិញ្ចើមសារជាថ្មីដើម្បីផ្ចង់ក្នុង ការត្រិះរិះ... មួយខណៈក្រោយគេពោលកាន់ខ្ញុំ ៖

រយៈពេលមួយនាទីរវាងភ្លើងដាច់ វិទ្យុលែងដំណើរការផ្សាយរហូតដល់ម៉ាស៊ីនភ្លើងត្រូវបានបញ្ឆេះ ឃាតកចង់សម្លាប់មនុស្សរួចគេចខ្លួនចេញពីស្ទូឌីយោលេខ៧វិញ ឃើញថាគ្មានបញ្ហាចោទទេ ប្រសិនបើគេចេះនូវវិធីបើកទ្វារបន្ទប់យ៉ាងស្ទាត់ជំនាញ ហេតុនេះ ឃាតកគឺស្ថិតនៅក្នុងចំណោមមនុស្សឧស្សាហ៍ចេញចូលបន្ទប់ផ្សាយដូច ដែលខ្ញុំបានសន្និដ្ឋានពីដំបូង... ។បងគិតឡើងវិញទៅមើល មានអ្នកណាម្នាក់ចេញពីការិយាល័យប្រជុំដែរទេ ក្នុងចំណោមបុគ្គលិកបងទាំង៣នាក់ ម៉ានិតដេត និងម៉ាណា និងនាយចូនី?

ខ្ញុំឆ្លើយតបវិញតាមការជជីកសួររបស់អធិការប៉ូលិសប្អូនប្រុសខ្ញុំ

មាន! ពេលដាច់ភ្លើងភ្លាម... ម៉ានិតដេត ចេញពីបន្ទប់ដើម្បីចុះទៅក្រោមបញ្ឆេះម៉ាស៊ីនភ្លើង ហើយម៉ាណានាងក្រោកចេញទៅក្រៅបន្ទប់ដែរ...នៅទីនោះមានតែបង ហើយនិងចូនីប៉ុណ្ណោះ។

វិចិត្រដំឡើងសំឡេង បន្ទាប់ពីការរៀបរាប់របស់ខ្ញុំ ៖

ត្រូវម៉ាច់! ម៉ានិតដេត និងម៉ាណា នេះគួរឲ្យសង្ស័យបំផុតហើយ... ម៉ានិតដេត អាចឆ្លៀតពេលចូលទៅក្នុងបន្ទប់ផ្សាយរឹតកសម្លាប់ឆវីរីន ហើយទើបចុះទៅបញ្ឆេះម៉ាស៊ីនជាក្រោយក៏ថាបាន...ហើយ

មួយទៀត… នាងម៉ាណាសុខៗម៉េចក៏សុខចិត្តចេញពីបន្ទប់ប្រជុំភ្លាមគ្រាន់តែ ដាច់ភ្លើងប៉ុណ្ណឹង? ពីរនាក់នេះគួរឲ្យសង្ស័យជាងគេហើយ…

**ងងឹត**

វិចិត្រ មិនទាន់បានបញ្ចប់ប្រយោគស្រួលបួលផង ភ្លើងត្រូវរលត់ភ្លឹបងងឹតស្លុបពេញការិយាល័យរបស់ខ្ញុំសាជាថ្មី… ខ្ញុំក្រោកពីកៅអីដោយមួហ្មង…

ស្អីគេហ្នឹង?… ភ្លើងម៉ាស៊ីនហើយក៏នៅតែរលត់ទៀតហ្ន៎ សង្ស័យអស់ប្រេងទេដឹង?

មិនទាន់ឈានចេញឆ្ងាយពីតុបានបីជំហានត្រឹមត្រូវផង ភ្លើងអំពូលបំភ្លឺពេញផ្ទៃបន្ទប់វិញស្រេចទៅហើយ ព្រមទាំងពេលនឹងសំរិបជើងអ្នកណាម្នាក់ឈានចូលមកដល់ក្នុង ការិយាល័យរបស់ខ្ញុំ។

.. ខ្ញុំងើបមុខ សម្លឹងទៅមើលជនចំណូលថ្មីដែលទើបនឹងចូលមកដល់… ខ្ញុំស្គាល់ថា គេនោះគឺជានាយប៉ូលិសមួយរូបដែលខ្ញុំទើបតែបាននិយាយនៅនឹងកន្លែង ឃាតកម្មមុននេះ… ខ្ញុំមិនទាន់ពោលទៅកាន់គេនោះថាយ៉ាងណាផង… នាយប៉ូលិសរូបនោះបន្លឺមកកាន់ពួកយើងមុនទៅហើយ ៖

មិនមែនម៉ាស៊ីនភ្លើងអស់ប្រេងទេ… តែខ្ញុំបិទភ្លើងអម្បាញ់មិញ ព្រោះចង់ពិសោធន៍អោយអ្នកទាំងពីរចូលរួមវិភាគអំពីបញ្ហាមួយ។

ខ្ញុំទើបនឹងដឹងថា ភ្លើងដែលរលត់ភ្លឹបមួយដង្ហើមអម្បាញ់មិញ គឺនាយប៉ូលិសរូបនេះបិទកុងតាក់ពីមាត់ទ្វារបន្ទប់ខាងក្រៅសោះ… ខ្ញុំក៏ងឿងឆ្ងល់ដែរថា គេចង់ពិសោធន៍ពីរឿងអ្វី… ខ្ញុំលើកដៃចង្អុលទៅសាឡុងដែលនៅចំពីមុខតុ…៖

អញ្ជើញអង្គុយ!

នាយប៉ូលិសវ័យក្មេងដាក់បង្គុយនៅលើសាឡុងតាមការអញ្ជើញរបស់ខ្ញុំ ភ្លាមនោះវិចិត្របន្លឺទៅកាន់គេ ៖

រកឃើញអ្វីខ្លះទេវិទូ? ពួកគេផ្តល់ចម្លើយយ៉ាងម៉េចខ្លះ?

ខ្ញុំខំផ្ទៀងត្រចៀកស្តាប់ដោយយកចិត្តទុកដាក់ ព្រោះខ្ញុំចង់ដឹងណាស់ថាប៉ូលិសរកឃើញអ្វីខ្លះហើយ… ប៉ូលិសឈ្មោះវិទូ បន្លឺដោយភាពហ្មត់ចត់ ៖

លោកម៉ានិតដេត ដែលជាពិធី ករធ្លាប់រួមការងារជាមួយអ្នករងគ្រោះជាង៥ឆ្នាំបាននិយាយថា ព្រឹកនេះគាត់បានចូលប្រជុំតាំងពីម៉ោង៨កន្លះ ហើយបានឮសំឡេងនាងឆវីរីនតាមវិទ្យុដែលបើកចោល

ក្នុងបន្ទប់ប្រជុំ រហូតដល់ម៉ោង៩កន្លះ ភ្លើងក៏ដាច់ វិទ្យុក៏លែងឮ ហើយខ្លួនគាត់បានចាកចេញពីបន្ទប់ប្រជុំ ចុះទៅជាន់ខាងក្រោម ដើម្បីបញ្ឆេះម៉ាស៊ីនភ្លើង នៅពេលដែលគាត់ឡើងមកវិញ ក៏ឮសំឡេងឆោឡោរបស់លោកនាយកវិសុទ្ធ និងលោកថូនី ពីការស្លាប់របស់ឆវីរីនក្នុងបន្ទប់ផ្សាយតែម្តង!

ខ្ញុំងក់ក្បាលផ្ងក់ៗទទួលថាពាក្យចម្លើយរបស់ម៉ានិតដេតមានភាព ត្រឹមត្រូវពិតប្រាកដ ឥតមានបន្លំមួយចំណុចណាមែន... ភ្លាមនោះនាយប៉ូលិសវិទូ ពោលបន្ត៖

ចំណែកម៉ាណាបានឲ្យចម្លើយមកថា នាងក៏បានទៅចូលរួមប្រជុំរហូតដល់ម៉ោង៩កន្លះ នៅពេលភ្លើងដាច់ នាងក៏បានចាកចេញពីបន្ទប់ប្រជុំដំណាលគ្នាជាមួយម៉ានិតដេតដែរ តែនាងមិនបានចុះទៅកន្លែងម៉ាស៊ីនភ្លើងជាមួយលោកម៉ានិតដេតទេ

អីចឹងនាងចេញទៅណា?(វិចិត្រសួរកាត់យ៉ាងរហ័ស)

វិទូប៉ូលិសវ័យក្មេងឆ្លើយតបវិញភ្លាម ៖

ម៉ាណាអះអាងថា នាងចេញពីបន្ទប់ប្រជុំនៅពេលនោះដើម្បីទៅកាន់បន្ទប់កាត់ត ត្រួតពិនិត្យFile សំឡេងមួយចំនួនដែលខ្លួនបានទុកចតចម្លងចោលនៅទីនោះ... នាងនិយាយថា នាងនៅរង់ចាំក្នុងបន្ទប់កាត់តរហូតដល់ភ្លើងត្រូវបានបញ្ឆេះឆេះ ឡើងវិញ រួចនាងរៀបចំចតបន្តទៀតរួចទើបចេញមកកាន់បន្ទប់ប្រជុំវិញ។ នាងជាអ្នកដឹងក្រោយគេថាស្ទូឌីយោលេខ៧មានរឿង ធ្វើឃាត ។ចំណែកលោកថូនី វិស្វករមកពីអាមេរិកនោះគាត់បានអះអាងថា តាំងពីពេលចូលប្រជុំរហូតដល់ពេលឃើញសាកសព គឺគាត់ចេញពីបន្ទប់ប្រជុំតែម្តងគត់ គឺនៅពេលដែលភ្លើងត្រូវបានបញ្ឆេះ ហើយឆវីរីន នៅតែមិនឮផ្សាយបន្ត គាត់ និងលោកនាយកវិសុទ្ធក៏ចេញពីបន្ទប់ប្រជុំទៅបន្ទប់ផ្សាយបើកទ្វារ ចូលទៅមើលនាង ពេលនោះគឺបានឃើញឆវីរីនស្លាប់លើកៅអីស្រេចទៅហើយ...

ខ្ញុំលើកដៃច្បូតមុខកម្ចាត់ភាពស្មុគស្មាញ រួចពោលទៅកាន់ប៉ូលិសទាំងពីរនាក់ដែលអង្គុយចំពោះមុខ ៖

អីចឹងមានតែលេខកូដស្ទូឌីយោលេខ៧ ក្រៅពីពួកបងប្អូននាក់នឹង នៅមានអ្នកផ្សេងដឹងទៀត?

ទោះនិយាយដូច្នេះមែន តែខ្ញុំប្រាប់ខ្លួនឯងស្ងាត់ៗហើយថា លេខសម្ងាត់សម្រាប់បើកទ្វារបន្ទប់ផ្សាយក្រៅពីខ្ញុំ ម៉ានិតដេត ម៉ាណា ថូនី និងឆវីរីន ផ្ទាល់គឺគ្មានអ្នកណាដឹងទៀតទេ ដូច្នេះឃាតកគឺពិតជាអ្នកណាម្នាក់ក្នុងចំណោមពួកយើងនេះឯង។

ខ្ញុំ និងចូនី នៅក្នុងបន្ទប់ការិយាល័យប្រជុំរហូតដល់ពេលឃើញសាកសព ដូច្នេះមនុស្សដែលគួរឲ្យសង្ស័យជាងគេ គឺមានតែ ម៉ានិតដេត និងម៉ាណា ដែលចេញពីបន្ទប់ប្រជុំទៅក្រៅក្នុងអំឡុងពេលភ្លើងដាច់។

ខ្ញុំងាកទៅរកវិចិត្រទាំងស្មុគស្មាញពេញណែនក្នុងគំនិត... ខ្ញុំសួរគេ ៖

ឯងគិតឃើញយ៉ាងម៉េច?

វិចិត្រឆ្លើយតបវិញដោយអាការៈនឹងន ៖

បងគិតឃើញហើយទេតើ ថាអ្នកណាគួរឲ្យសង្ស័យបំផុតនោះ!

ខ្ញុំទ្រោបក្បាលនៅលើតុទាំងតប់ប្រមល់ បើមានលទ្ធភាពខ្ញុំសុំយ៉ាងណាឲ្យឃាតក គ្មានក្នុងចំណោមបុគ្គលិកក្រោមបង្គាប់ខ្ញុំទៅចុះ ព្រោះខ្ញុំបានបាត់បង់ឆវីរីនម្នាក់ហើយ ខ្ញុំមិនចង់ឲ្យបាត់បង់អ្នកណាម្នាក់ទៀតទេ ខ្ញុំពោលសួរទាំងល្វើយ ៖

ឯងសង្ស័យ ម៉ានិតដេត និងម៉ាណា អ្ហេស?

វិចិត្របន្លឺទាំងញាក់ចិញ្ចើម

មនុស្សពីរនាក់ នេះត្រូវជាប់សង្ស័យធ្ងន់ដូចគ្នា ។តាមសង្កេតលើចម្លើយ និងស្ថានការណ៍រួម គឺនាយម៉ានិតដេត... អាចឆ្លៀតពេលភ្លើងដាច់ភ្លាមចេញពីបន្ទប់ប្រជុំ ហើយយកលេសថាចុះទៅក្រោមបញ្ឆេះម៉ាស៊ីនភ្លើង... តែ... នរណាហ៊ានធានាថា គេនោះមិនចូលទៅបន្ទប់ផ្សាយសម្លាប់អ្នករងគ្រោះជាមុន រួចទើបចុះទៅបញ្ឆេះម៉ាស៊ីនជាក្រោយ? ... គេចាំឲ្យភ្លើងឆេះបានបន្តិច ក៏ឡើងមកកាន់បន្ទប់ប្រជុំសាជាថ្មី ធ្វើដូចជាគ្មានរឿងអ្វីកើតឡើងទាំងអស់

ខ្ញុំពោលកាត់ដោយមិនជឿជាក់ ៖

បងដូចជាមិនចង់ជឿ គេហ៊ានប្រថុយចូលទៅសម្លាប់ឆវីរីន មុនពេលចុះទៅបញ្ឆេះម៉ាស៊ីននោះទេ ព្រោះបន្ទប់ផ្សាយនៅឆ្ងាយពីបន្ទប់ប្រជុំមិនដល់៣ម៉ែត្រផង... គេមិនខ្លាចបង ឬចូនី ចេញពីបន្ទប់មកទាន់ទេហ្អី?

វិចិត្រពោលកាត់វិញបញ្ចប់ភាពងឿងឆ្ងល់របស់ខ្ញុំ ៖

ឃាតកតែងមានល្បិចច្រើនណាស់ រហូតដល់រឿងខ្លះសុទ្ធតែយើងស្មានមិនដល់ផង ...

ខ្ញុំហៀបនឹងពោលបន្តទៅហើយ តែភ្លាមនោះ នាយវិទូ ប៉ូលិសក្មេងពោលឡើងម្តង ៖

តែសម្រាប់ខ្ញុំ... មនុស្សពីរនាក់នេះ គ្មានពេលគ្រប់គ្រាន់ដើម្បីចូលទៅសម្លាប់អ្នករងគ្រោះទេ។

ខ្ញុំអរភើ ត ព្រោះនឹកថា ប្រហែលជានាយប៉ូលិសវិទូមានទឡ្ហីករណ៍អ្វីផ្សេងពីវិចិត្រ ដែលហោច ណាស់ក៏ អាចរំដោះម៉ាណានិងម៉ានិតដេតចេញពីចំណោមជនសង្ស័យដែរ។

ខ្ញុំ សម្លឹងទៅគេរង់ចាំស្តាប់ដោយអន្ទះសា ខណៈនោះគេបន្លឺ មួយៗ៖

មុននឹងខ្ញុំអះអាងចំពោះបញ្ហានេះ ខ្ញុំចង់អញ្ជើញអ្នកទាំងពីទៅកាន់ស្ទូឌីយោលេខ៧ដើម្បីពិនិត្យមើល សភាពនៅទីនោះ...

ពួកយើងនាំគ្នាចេញពីការិយាល័យរបស់ខ្ញុំ ដែលកាលពីព្រឹក ខ្ញុំ និងសហការីបានប្រជុំនៅទីនោះ។ បន្ទប់ផ្សាយនៅទល់មុខការិយាល័យខ្ញុំ ដោយឃ្លាតពីគ្នាមិនដល់៣ម៉ែត្រផង ឯបន្ទប់កាត់តគឺស្ថិតនៅ ខាងឆ្វេងដែជាប់គ្នានឹងបន្ទប់ផ្សាយដែរ... អារម្មណ៍របស់ខ្ញុំផ្ទាល់បង្ហាញថា នាងម៉ាណាគួរត្រូវប៉ូលិស សង្ស័យជាងគេ ព្រោះបន្ទប់កាត់តដែលនាងចេញទៅមើលការ ថតSoundនិងបន្ទប់ផ្សាយនៅក្បែរ គ្នាណាស់ ចុះហេតុអ្វីបានជានាយវិទូហ៊ានអះអាងថា ម៉ានិតដេត និងម៉ាណាគ្មានពេលគ្រប់គ្រាន់ ដើម្បីសម្លាប់អ្នករងគ្រោះទេ?

ស្ថានភាពនៅទីនេះស្ងាត់ជ្រងំ តាមមើលក្រុមប៉ូលិសនាំគ្នាសួរចម្លើយបុគ្គលិកខ្ញុំរួច ក៏អនុញ្ញាតឲ្យ ត្រលប់ទៅផ្ទះវិញអស់ហើយមើលទៅ ខ្ញុំលូកដៃវាវលេខបើកទ្វារបន្ទប់ផ្សាយរួចច្រានទៅខាងក្នុង...

ផ្ទៃបន្ទប់ទាំងមូលងងឹតស្លុប សម្លឹងតែបាតដៃខ្លួនឯងក៏មិនឃើញផង... ព្រោះជាបន្ទប់បិទជិតគ្មាន បង្អួច ឬស្លាបព្រិលសូម្បីតែមួយឡើយ... ខ្ញុំលូកដៃរាវចុចកុងតាក់ភ្លើង... ភ្លើងបំភ្លឺបន្ទប់ដែលស្ងាត់ សូន្យ គ្មានឃើញស្រមោលមនុស្សម្នាក់... មានតែម៉ាស៊ីនផ្សាយ និងកៅអីទទេ ដែលកាលពីព្រឹកឆរីវី ន ត្រូវគេសម្លាប់នៅទីនេះ ខ្ញុំងាកទៅរកវិចិត្រ និងនាយវិទូ ដែលឈានចូលមកតាមពីក្រោយជា សញ្ញាថាខ្ញុំកំពុង រង់ចាំស្តាប់ការរកឃើញរបស់គេ។

នាយវិទូដើរទៅក្បែរកៅអីបង្វិលដែលពិធីករនីមួយៗ តែងតែអង្គុយក្នុងពេលដំណើរការផ្សាយ គេ បង្វិលកៅអីចុះឡើងពីរបី ដងទើបពោលមកកាន់ខ្ញុំ ៖

ពេលឃើញសាកសព... គឺអ្នករងគ្រោះស្ថិតនៅក្នុងស្ថានភាពត្រូវគេសម្លាប់លើកៅអីនេះ ដោយរឹតក ពីក្រោយ... បានន័យថា ... នាងត្រូវគេសម្លាប់នៅពេលនាងកំពុងអង្គុយលើកៅអី... ប៉ុន្តែលោក អធិការ និងលោកនាយកឆ្ងល់ទេថា ប្រសិនបើឃាតកវាចូលមកបន្ទប់នាង អំឡុងពេលដែលភ្លើ ងដាច់... ហេតុអ្វីក៏នាងនៅអង្គុយលើកៅអីនៅឡើយ? អម្បាញ់មិញ នៅក្នុងការិយាល័យលោក

នាយក ខ្ញុំបានពិសោធន៍រួចហើយ... ខ្ញុំចុចភ្លើងបិទពីក្រៅមិនដល់មួយនាទីផង លោកស្ទុះក្រោកពីលើកៅអីទៅហើយ... នេះជាប្រតិកម្មធម្មតារបស់មនុស្ស... មនុស្សមិនចេះទ្រាំអង្គុយស្ងៀមបានទេនៅក្នុងស្ថានភាពភ្លឺហើយស្រាប់តែរលត់ភ្លើងងងឹតមើលបាតដៃខ្លួន មិនឃើញ ហើយពេលនោះភ្លើងដាច់ ម៉ាស៊ីនផ្សាយលែងដំណើរការទៀត មានរឿងអីដែលថាអ្នកនាងឆវីរីន នៅអង្គុយស្ងៀមលើកៅអីបណ្តោយឃាតកឲ្យចូលមករឹតកសម្លាប់បាន?

ខ្ញុំក៏យល់ដូចសម្តីរបស់នាយប៉ូលិសរូបនេះដែរ... ខ្ញុំជឿថាក្នុងពេលដែលភ្លើងរលត់នោះ ... ឆវីរីនមុខជាដើរពីកៅអី ដើរចេញមកក្រៅមិនខាន... នាងមិនអាចទ្រាំអង្គុយស្ងៀមនៅលើកៅអីបន្តទៀតទេ... ព្រោះទីនេះងងឹតខ្លាំងណាស់ ខ្ញុំមិនទាន់ហើបមាត់ថាយ៉ាងណាផង ខ្ញុំឮនាយវិទូពោលបន្ថែមភ្លាម ៖

បានន័យថា នៅពេលដែលឃាតកចូលមកសម្លាប់នាង គឺមិនមែនជាពេលភ្លើងដាច់ទេ នាងអាចត្រូវគេសម្លាប់នៅមុនពេលភ្លើងដាច់ ឬក្រោយពេលម៉ាស៊ីនភ្លើងបញ្ឆេះសារជាថ្មី ព្រោះទាល់តែក្នុងបន្ទប់ផ្សាយមានភ្លើងទើបសុខចិត្តអង្គុយលើកៅអី នេះ ...

ខ្ញុំលូកមាត់សួរកាត់វិញ ទាំងក្តីភ្ញាក់ផ្អើលពេញបន្ទុក ៖

លោកចង់និយាយថា ...

វិទូងក់ក្បាលផ្ងក់ៗតបមកកាន់ខ្ញុំវិញ ៖

លោកនាយកបានមានប្រសាសន៍ថា លោកឮសំឡេងជនរងគ្រោះតាមវិទ្យុរហូតដល់ពេលភ្លើងដាច់ទើបឈប់ឮ... ដូច្នេះយើងអាចសន្និដ្ឋានបានថា... នាងនៅមានជីវិតនៅឡើយទេនៅពេលនោះ... ហើយរហូតដល់ពេលភ្លើងដាច់ក៏នាងនៅមានជីវិតដែរ តែគឺពេលភ្លើងត្រូវគេបញ្ឆេះឲ្យភ្លឺសាជាថ្មីនោះទេ... ដែលនាងត្រលប់ចូលទៅអង្គុយរៀបចំផ្សាយសាជាថ្មី ក៏ត្រូវគេសម្លាប់តែម្តង...

ខ្ញុំពិចារណាស្ងាត់ៗក្នុងចិត្តដោយក្តីរារែក... ថ្វីត្បិតតែសម្តីរបស់នាងប៉ូលិសវ័យក្មេងរូបនេះ មានហេតុមានផលគួរឲ្យពិចារណាក៏ពិតមែន តែ... ក្នុងរយៈពេលដែលភ្លើត្រូវបញ្ឆេះឲ្យភ្លឺវិញ ឃាតកឆ្លៀតចូលទៅសម្លាប់នាងក្នុងបន្ទប់ផ្សាយ... ហើយគេចខ្លួនចេញវិញគឺប្រចុចញ៉ុចសម្បើមណាស់ ព្រោះគ្រាន់តែភ្លើងត្រូវបញ្ឆេះឲ្យភ្លឺឡើងវិញ ហើយខ្ញុំលែងឮសំឡេងឆវីរីនផ្សាយតាមវិទ្យុ ខ្ញុំ និងថូនីក៏ស្ទុះចូលទៅកាន់បន្ទប់ផ្សាយភ្លាម... រយៈពេលខ្លីដូច្នេះ ឃាតកអាចសម្លាប់មនុស្សហើយគេចចេញពីបន្ទប់ផ្សាយវិញភ្លាមៗដោយវិធី ណា?

សំឡេងវិចិត្រលាន់មកកាត់ផ្តាច់អារម្មណ៍ស្មុគស្មាញរបស់ខ្ញុំ៖

វិទូ! ... ចុះម៉េចក៏មិនសង្ស័យថាឃាតកចូលមកបន្ទប់ផ្សាយតាំងពីពេលដែលភ្លើង មិនទាន់ដាច់ ហើយវាឆ្លៀតពេលដែលភ្លើងដាច់ភ្លាម ក៏រឹតកសម្លាប់នាងពីក្រោយដោយមិនទុកឲ្យនាងក្រោកពីកៅអីទាន់ នោះ?...

វិទូញាក់ស្មាតបរិញ ៖

តែពេលនោះ មនុស្ស៤នាក់ទៀតដែលចេះបើកសោសម្ងាត់ទ្វាស្ទូឌីយោលេខ៧កំពុងនៅ ប្រជុំគ្នានៅឡើយទេ ទាល់តែពេលភ្លើងដាច់ ទើបពួកគាត់បំបែកគ្នាចេញពីបន្ទប់ប្រជុំ តើមានមនុស្សផ្សេងណាម្នាក់ទៀតដែលអាចចូលទៅបន្ទប់ផ្សាយនៅមុនពេល ភ្លើងដាច់ ហើយដល់ពេលដែលភ្លើងដាច់ គេក៏សម្លាប់នាងភ្លាមទាំងនៅលើកៅអីនោះ?

វិចិត្រលើកដៃកាត់ ដោយនិយាយផ្ទូង ហាក់បីដូចជាទើបនឹងនឹកឃើញដល់រឿងអ្វីមួយ ៖

ចុះនាងទុំក្មេងលើកទឹកនោះ? .. ថ្វីត្បិតនាងមិនចេះបើកទ្វារបន្ទប់ផ្សាយមែន តែជួនកាលពេលនោះ នាងឡើងមករកឆវីន ជនរងគ្រោះ ហេតុតែគិតថាជាអ្នកធ្វើការជាមួយគ្នាក៏បើកទ្វារបន្ទប់ផ្សាយឲ្យចូល ប៉ុន្តែក្មេងលើកទឹកនោះនៅក្នុងបន្ទប់ផ្សាយដល់ពេលភ្លើងដាច់ភ្លាម  ក៏រឹតកសម្លាប់អ្នករងគ្រោះតែម្តង ទើបគេចខ្លួនចេញក៏ថាបាន!...

ខ្ញុំហៀបនឹងបដិសេធការសន្និដ្ឋាននេះទៅហើយ តែត្រូវវិទូ ពោលកាត់មុន ៖

ក្មេងស្រីនោះ មិនមានលទ្ធភាពសម្លាប់ជនរងគ្រោះនោះទេ! ...អម្បាញ់មិញ នៅពេលសួរចម្លើយ... យើងបានពិនិត្យឃើញថា នាងមានលក្ខណៈពិការដៃឆ្វេង ដូច្នេះពឹងលើដៃស្តាំតែម្ខាង ថ្វីត្បិតនាងអាចធ្វើការងារស្រាលៗ ដូចជាដៃទឹក លើកកែវទឹក បោសធូលី ... ដៃឆ្វេងនាងគ្មានកម្លាំងគ្រប់គ្រាន់សម្រាប់ជួយដៃស្តាំក្នុងការ រឹតកសម្លាប់មនុស្សឡើយ... ហេតុនេះនាងត្រូវផាត់ចេញពីចំណោមអ្នកដែលត្រូវសង្ស័យ។

ខ្ញុំលាន់មាត់ពោលបន្តពីសម្តីប៉ូលិសរូបនោះ ៖

ត្រូវហើយ... នាងទុំធ្លាប់ធ្លាក់ពីលើដើមឈើ ហេតុនេះដៃឆ្វេងរបស់នាងត្រូវបាត់បង់ថាមពល... ដោយក្រៅពីពីការងារស្រាលៗ នាងមិនអាចប្រើដៃទាំងពីររួមគ្នាឡើយ... ហើយខ្ញុំចាំបានថា... នៅមុនពេលភ្លើងដាច់នោះ ថូនីបានទូរស័ព្ទទៅបន្ទប់ខាងក្រោមដើម្បីហៅនាងឲ្យឆុងកាហ្វេមក ឲ្យគេ ព្រោះម្នាក់នេះចូលចិត្តកាហ្វេខ្មៅសុទ្ធ ហើយមិនដាក់ស្ករទៀត នេះបញ្ជាក់ថា ពេលនោះនាងទុំនៅ

បន្ទប់បាយខាងក្រោយនៅឡើយទេ នាងមិនបានឡើងមកបន្ទប់ផ្សាយដូចការសន្និដ្ឋានរបស់វិចិត្រអម្បាញ់មិញនេះទេ!

វិចិត្រងក់ក្បាលផ្ងក់ៗ ... គេពោលទាំងងើយក្បាលដកដង្ហើមវែង ៖

អីចឹងយើងនៅតែគិតថា ឆវីរីន ពេលភ្លើងដាច់នឹងមិនទាន់ត្រូវគេសម្លាប់នៅឡើយទេ ព្រោះភ្លើងដាច់នាងមានរឿងអីអង្គុយលើកៅអីទៀតនោះ... ទាល់តែពេលភ្លើងត្រូវបំភ្លឺសាជាថ្មី ទើបនាងអង្គុយលើកៅអីសាជាថ្មី ដើម្បីត្រៀមផ្សាយ គឺពេលនោះឯងដែលនាងត្រូវគេរឹតកសម្លាប់ ...

ខ្ញុំមិនរង់ចាំឲ្យវិចិត្រនិយាយចប់ទាន់នោះទេ ខ្ញុំពោលកាត់ ៖

តែរយៈពេលភ្លើងឆេះភ្លាម បងនិងចូនី ដែលអង្គុយចាំស្តាប់វិទ្យុក្នុងបន្ទប់ប្រជុំ ពេលមិនឮសំឡេងឆវីរីនផ្សាយ ក៏ដើរសំដៅមកបន្ទប់ផ្សាយភ្លាម ... ទោះបីឃាតករហ័សយ៉ាងណាក៏មិនអាចប្រើពេល១នាទី ក្រោយភ្លើងឆេះនេះសម្លាប់ឆវីរីន ហើយគេចខ្លួនបាត់ មុនពេលបង និងចូនីចូលទៅដល់នោះទេ!

ក្រសែភ្នែកប៉ូលិសវ័យក្មេងវិទូសម្លឹងមកខ្ញុំយ៉ាងមុតហាក់បីដូច ជាបង្កប់ជាមួយនូវគំនិតអ្វីម្យ៉ាងមិនប្រក្រតីល្មមឲ្យខ្ញុំភ្ញាក់ ផ្អើល... គេពោលមួយៗសាជាថ្មី ៖

យើងពិចារណាពីម៉ានិតដេត ម្នាក់នេះចាកចេញពីបន្ទប់ប្រជុំចុះទៅជាន់ខាងក្រោម ដើម្បីបញ្ឆេះម៉ាស៊ីនភ្លើង... ដល់ពេលភ្លើងត្រូវបញ្ឆេះឲ្យភ្លឺគេឡើងមកវិញ ក៏ឃើញជនរងគ្រោះត្រូវគេសម្លាប់បាត់ទៅហើយ... ដូច្នេះគេត្រូវផាត់ចេញពីចំណោមអ្នកដែលត្រូវសង្ស័យ ព្រោះក្នុងរយៈពេលមួយនាទី... គេមិនអាចឡើងមកសម្លាប់មនុស្ស ហើយគេចទៅជាន់ខាងក្រោមវិញបានទាន់ពេលនោះឡើយ...

វិចិត្រពោលសួរវិញភ្លាម ៖

ចុះនាងម៉ាណា?

វិទូគ្រវីក្បាលបដិសេធ ៖

នាងក៏មិនអាចចូលទៅសម្លាប់ឆវីរីនទាន់ពេលនោះដែរ... សូមអ្នកទាំងពីរពិចារណាមើលចុះ រយៈពេលមួយនាទី សម្រាប់រឹតកអ្នករងគ្រោះដែលជាមនុស្សពេញកម្លាំងមិនមែនជារឿងងាយ ទេ... នាងមានពេលឯណានឹងគេចចេញពីបន្ទប់ផ្សាយ... បើនាងចូលទៅសម្លាប់អ្នករងគ្រោះមែន ហេតុអ្វីពេលគេចចេញវិញ នាងមិនជួបលោកនាយកវិសុទ្ធ និងនាយចូនី បើអ្នកទាំងពីរអះអាងថា បានចាកចេញពីបន្ទប់ប្រជុំភ្លាមនៅពេលដែលភ្លើងឆេះ ហើយមិនឮឆវីរីនផ្សាយនោះ?

ខ្ញុំដកដង្ហើមយូរ ធូរទ្រូងជាងមុន កាលបើដឹងថា អ្នកទាំងពីររួចផុតពីការសង្ស័យរបស់ប៉ូលិស... ខ្ញុំមិនទាន់បានពោលតបថា យ៉ាងណាផង... សំឡេងប្រកបដោយសភាពហ្មត់ចត់របស់នាយប៉ូលិសវ័យក្មេងវិទូ ពោលមកកាន់ខ្ញុំ ៖

លោកនាយក!... ពឹងផ្អែកលើស្ថានភាពដែលខាងប៉ូលិសយើងទទួលបាន និងពិចារណាតាមលក្ខណៈបច្ចេកទេសខ្ញុំគួរនិយាយត្រង់ៗថា ក្នុងហេតុការណ៍បែបនេះ ទោះបីក្រុមជំនាញណាមកធ្វើការអង្កេត... ក៏ជនដែលត្រូវសង្ស័យបំផុត... គឺមានតែលោក និងនាយថូនីវិស្វករមកពីបរទេសនោះឯង...

ខ្ញុំភ្ញាក់ដូចជាន់ចំក្បាលពស់វែក ដោយងើបមុខសម្លឹងទៅនាយប៉ូលិសវ័យវិទូយ៉ាងរហ័ស... រស្មីមុតថ្លានៃក្រសែភ្នែកដែលជះព្រិចៗមកចំខ្ញុំ ក៏ល្មមធ្វើឲ្យខ្ញុំដឹងថា ម្នាក់នេះមិនមែនកំពុងនិយាយកំប្លែងលេងមកកាន់ខ្ញុំនោះឡើយ...។ខ្ញុំ ហាក់មានអារម្មណ៍មួហ្មង ខ្ញុំត្រឡប់សួរទៅគេវិញមួយរំពេច ៖

លោកសង្ស័យខ្ញុំអ្ហែស?ខ្ញុំជាអ្នកឃាតកសម្លាប់កូនចៅឯង?

វិទូតបមកខ្ញុំវិញដោយអាកប្បកិរិយាមិនញញើត ៖

គិតមើលទៅ! ចន្លោះពេលដែលអ្នករងគ្រោះត្រូវគេសម្លាប់ គឺលោក និងនាយថូនីនៅក្នុងបន្ទប់ប្រជុំរង់ចាំភ្លើងឆេះ ពោលគឺលោកមិនបានរវល់កិច្ចការអ្វីផ្សេងដូចអ្នកដទៃឡើយ លោកឆ្លៀតពេលក្រោកទៅកាន់បន្ទប់ផ្សាយនៅពេលភ្លើងទើបតែត្រូវបាន បញ្ឆេះ បន្ទាប់មកលោកក៏ស្រែកប្រកាសឆោឡោឲ្យគ្រប់គ្នាដឹងពីមរណភាពរបស់នាងតែម្តង!